# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ៥៦៦ សជណ

# សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**<u>ជម្រាបមក</u>**

# ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**<u>កម្មវត្ថុ</u>:** ស្តីពីការដោះលែង និងលើកលែងការចោទប្រកាន់ពិរុទ្ធជន និងទណ្ឌិត ដោយតុលាការក្រុងភ្នំពេញចាប់ពីដើមឆ្នាំ២០០៣ ដល់ខែមិថុនា ឆ្នាំ២០០៤ ។

**<u>យោង</u>:** របាយការណ៍លេខ ២៨២ របក ចុះថ្ងៃទី២៩-០៦-២០០៤ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ។

-ចំណារឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី៣០-០៦-២០០៤ ។

តាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ចាប់ពីដើមឆ្នាំ២០០៣ រហូតមកដល់ ខែមិថុនា ឆ្នាំ២០០៤ នេះ ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា តុលាការក្រុងភ្នំពេញបានធ្វើការដោះលែង និងលើកលែងការចោទប្រកាន់ពិរុទ្ធជន និងទណ្ឌិតដែលប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងចំនួនមួយគួរអោយកត់សម្គាល់ ដែលមានចំនួនសរុប ២៧៤ (ស្រី៣៩នាក់) គឺក្នុងនោះរួមមាន ៖

-ពិរុទ្ធជន និងទណ្ឌិតដែលបានដោះលែង ឬលើកលែងការចោទប្រកាន់បន្ទាប់ពីបានឃុំខ្លួនក្រោមរយៈពេល ០១ឆ្នាំ មានចំនួន ១៦២នាក់ ។

-ទណ្ឌិតដែលបានដោះលែងបន្ទាប់ពីជាប់ក្នុងពន្ធនាគារលើសពី១១ឆ្នាំ មានចំនួន១១២នាក់ ។

ការដោះលែង និងលើកលែងការចោទប្រកាន់ខាងលើនេះ មានករណីខ្លះបានស្តែងចេញពីភាពមិនប្រក្រតីមួយចំនួន ៖

**<u>ទី១</u>**-ការផ្តន្ទាទោសមានកម្រិតអប្បបរមា បើប្រៀបធៀបទៅនឹងបទល្មើសដែលបានប្រព្រឹត្ត។

**<u>ទី២</u>**-យោងតាមច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី០៧ មករា ឆ្នាំ២០០២ នៅក្នុងមាត្រា៨ ការព្យួរទោស បានចែងថាចំពោះបទឧក្រិដ្ឋ និងបទឱ្យក្រិដ្ឋតម្រូវអោយធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមាព្យួរទោសបានឡើយ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាជ្រាប និងពិនិត្យករណីខាងលើនេះ តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ អំពីយើងខ្ញុំ ។

សូមជូនភ្ជាប់មកជាមួយនូវ បញ្ជីរាយនាមពិរុទ្ធជន និងទណ្ឌិតបទឧក្រិដ្ឋដែលតុលាការដោះលែងដើមឆ្នាំ ២០០៣ ដល់ខែ០៦-២០០៤ របស់ស្នងការដ្ឋាននគរបាលរាជធានីលេខ ៤៩៦ ប.ន ចុះថ្ងៃទី២១ មិថុនា ២០០៤ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤

**ជ.សហរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ព្រុំ សុខា**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-អគ្គស្នងការដ្ឋាននគបាលជាតិ
-អគ្គនាយកដ្ឋយរដ្ឋបាល
-ឯកសារ-កលប្បវត្តិ